ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# រាជរដ្ឋាភិបាលកម្ពុជា

# គោលនយោបាយជាតិ

## ស្តីពី

# សុវត្ថិភាពចរាចរណ៍ផ្លូវគោក

បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី

ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៤

**រៀបចំដោយគណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក**

# មាតិកា


១- សេចក្តីផ្តើម ... ១

២- ចក្ខុវិស័យ ... ៣

៣- គោលបំណងនិងគោលដៅ ... ៣

៣.១- គោលបំណង ... ៣

៣.២- គោលដៅ ... ៣

៤- យុទ្ធសាស្ត្រ ... ៣

៤.១- ការអប់រំនិងការផ្សព្វផ្សាយ ... ៣

៤.២- ការពង្រឹងការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ... ៣

៤.៣- ការយកចិត្តទុកដាក់លើអ្នកប្រើប្រាស់ផ្លូវថ្នល់ដែលងាយរងគ្រោះថ្នាក់ ... ៤

៤.៤- ការពង្រឹងផ្នែកវិស្វកម្មសុវត្ថិភាពផ្លូវថ្នល់ ... ៤

៤.៥- ការពង្រឹងប្រសិទ្ធភាពនៃសេវាសង្គ្រោះបឋមនិងសង្គ្រោះបន្ទាន់ ... ៤

៤.៦- ពង្រឹងការបណ្តុះបណ្តាលអ្នកបើកបរនិងការត្រួតពិនិត្យយានយន្ត ... ៤

៤.៧- ពង្រឹងការគ្រប់គ្រងទិន្នន័យនិងការស្រាវជ្រាវគ្រោះថ្នាក់ចរាចរណ៍ ... ៥

៤.៨- ពង្រឹងការគ្រប់គ្រងទៅលើសុវត្ថិភាពដឹកជញ្ជូនអ្នកដំណើរនិងទំនិញ ... ៥

៥- ផែនការសកម្មភាព ... ៥

៥.១- យន្តការអនុវត្ត ... ៥

៥.២- ការបង្កើតក្របខ័ណ្ឌគតិយុត្ត ... ៥

៥.៣- ការគាំទ្រហិរញ្ញវត្ថុ ... ៥

៥.៤- ការបណ្តុះបណ្តាលធនធានមនុស្ស ... ៦

៥.៥- ដំណើរការអនុវត្តគម្រោង ... ៦

៦- ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃ ... ១២

៧- សេចក្តីសន្និដ្ឋាន ... ១២

# ១- សេចក្តីផ្តើម

គ្រោះថ្នាក់ចរាចរណ៍ផ្លូវគោកជាបញ្ហាប្រឈមដ៏ធំមួយ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ គ្រោះថ្នាក់ចរាចរណ៍ផ្លូវគោកមិនអាចចៀសផុតបានឡើយ ប៉ុន្តែបញ្ហាប្រឈមនេះយើងអាចកាត់បន្ថយនិងការពារបាន។ គ្រោះថ្នាក់ចរាចរណ៍ផ្លូវគោក គឺជាវិញ្ញាសាមួយដ៏សំខាន់បំផុតដែលទាក់ទងនឹងអាយុជីវិត មនុស្ស សត្វ និងបរិស្ថានសង្គមទាំងមូល។ បញ្ហាប្រឈមដ៏ធ្ងន់ធ្ងរនេះមិនអាចឲ្យក្រសួង ស្ថាប័ន ឬផ្នែកណាមួយធ្វើការទប់ស្កាត់ កាត់បន្ថយ ឬលុបបំបាត់បានឡើយ ប៉ុន្តែយើងអាចសហការគ្នាទប់ស្កាត់និងកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោកនេះ ឲ្យថយមកនៅកម្រិតទាបបំផុត។ គោលនយោបាយជាតិស្តីពីសុវត្ថិភាពចរាចរណ៍ផ្លូវគោក គឺជាមធ្យោបាយដ៏មានសក្តានុពល និងជាកត្តាគន្លឹះធ្វើជាត្រីវិស័យសម្រាប់រក្សាសន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាពដល់អ្នកប្រើប្រាស់ផ្លូវថ្នល់ នៅលើដងផ្លូវថ្នល់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ រាជរដ្ឋាភិបាលបានលើកទឹកចិត្តនិងជំរុញឲ្យគ្រប់ផ្នែក គ្រប់វិស័យឲ្យយកចិត្តទុកដាក់ខ្ពស់ចំពោះបញ្ហាសុវត្ថិភាពចរាចរណ៍ផ្លូវគោកដែលរាល់ការចំណាយលើសកម្មភាពទាំងអស់នេះត្រូវបានចាត់ទុកថាជាការធ្វើវិនិយោគមួយសម្រាប់ជួយបញ្ចៀសប្រជាជនឲ្យរួចផុតពីគ្រោះមហន្តរាយដ៏ធំមួយរបស់សង្គមជាតិ។

នៅក្នុងឆ្នាំ២០០១ រាជរដ្ឋាភិបាលបានឯកភាពជាមួយនឹងអង្គប្រជុំរបស់សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (ASEAN)ស្តីពីសុវត្ថិភាពចរាចរណ៍ផ្លូវគោក ដោយធ្វើការប្តេជ្ញាក្នុងរយៈពេលវែងក្នុងការកាត់បន្ថយអត្រាគ្រោះថ្នាក់ចរាចរណ៍និងជនរងគ្រោះដោយគ្រោះថ្នាក់ចរាចរណ៍ នៅក្នុងតំបន់អាស៊ីអាគ្នេយ៍។

ដើម្បីអនុវត្តគោលនយោបាយជាតិឲ្យមានប្រសិទ្ធភាពខ្ពស់ ត្រូវទាមទារការចូលរួមជាមួយរាជរដ្ឋាភិបាល ពីអង្គការមិនមែនរដ្ឋាភិបាលនិងវិស័យឯកជនមកពីគ្រប់មជ្ឈដ្ឋានជាតិនិងអន្តរជាតិ។ ចំពោះការសម្របសម្រួលនិងត្រួតពិនិត្យលើគោលនយោបាយជាតិនេះ នឹងត្រូវទទួលខុសត្រូវដោយគណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក។

រាជរដ្ឋាភិបាលផ្តល់អាទិភាពខ្ពស់ទៅលើការលើកកម្ពស់ និងជំរុញការអនុវត្តគោលនយោបាយជាតិស្តីពីសុវត្ថិភាពចរាចរណ៍ផ្លូវគោក ការគោរពច្បាប់ បទប្បញ្ញត្តិចរាចរណ៍នានាការកែប្រែឥរិយាបថក្នុងសង្គម ដែលមិនយកចិត្តទុកដាក់គោរពច្បាប់ចរាចរណ៍ក្នុងពេលធ្វើដំណើរនៅលើដងផ្លូវ។ ការអនុវត្តគោលនយោបាយជាតិស្តីពីសុវត្ថិភាពចរាចរណ៍ផ្លូវគោកប្រកបដោយប្រសិទ្ធភាពនេះ គឺពិតជាមានសារៈសំខាន់ខ្លាំងណាស់សម្រាប់ទប់ស្កាត់ កាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោកនៅក្នុងព្រះរាជាណាចក្រកម្ពុជា តាមគោលដៅដែលបានកំណត់ គឺកាត់បន្ថយចំនួនអ្នកស្លាប់និងអ្នករងរបួសឲ្យមកនៅកម្រិតទាបបំផុត។

គោលនយោបាយនេះគឺជាទិសដៅមូលដ្ឋានមួយសម្រាប់សុវត្ថិភាពចរាចរណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយនឹងត្រូវធ្វើការកែតម្រូវប្រសិនបើចាំបាច់ ដោយអនុលោមតាមគោលនយោបាយរបស់អង្គការសហប្រជាជាតិនិងរបស់អាស៊ាន និងទំនោរនៃគ្រោះថ្នាក់ចរាចរណ៍នៅពេលអនាគតនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ កត្តាជោគជ័យនៃគោលនយោបាយនេះនឹងផ្អែកលើការអនុវត្តផែនការសកម្មភាពជាតិទសវត្សរ៍សុវត្ថិភាពចរាចរណ៍ផ្លូវគោកឆ្នាំ២០១១-២០២០។

នៅក្នុងព្រះរាជាណាចក្រកម្ពុជា ប៉ុន្មានឆ្នាំចុងក្រោយនេះ កំណើនយានយន្តមាន១៦%ជាមធ្យមក្នុងមួយឆ្នាំ ហើយក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ ចំនួនអ្នកស្លាប់និងអ្នករងរបួសបានកើនឡើងគួរឲ្យព្រួយបារម្ភ បង្កជាកង្វល់ដ៏ធំសម្រាប់រាជរដ្ឋាភិបាលកម្ពុជា។

អត្រាស្លាប់មានចំនួន១០នាក់ក្នុងយានយន្ត១០ ០០០គ្រឿង ក្នុងឆ្នាំ២០១១ នៅតែធ្វើឲ្យព្រះរាជាណាចក្រកម្ពុជាមានអត្រាអ្នកស្លាប់ដោយគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោកខ្ពស់ជាងគេនៅក្នុងតំបន់អាស៊ាន។ ទោះបីជាអត្រាស្លាប់ក្នុងយានយន្ត១០ ០០០គ្រឿង បានថយចុះពី១១នាក់ នៅឆ្នាំ២០១០ មក១០នាក់ នៅឆ្នាំ២០១១ក៏ពិតមែន ប៉ុន្តែចំនួនអ្នកស្លាប់សរុបជាក់ស្តែងនិងអត្រាស្លាប់ក្នុងចំណោមប្រជាជន១០០ ០០០នាក់ នៅតែបន្តកើនឡើងពី១២,៧នាក់ក្នុងឆ្នាំ២០១០ដល់១៣,១នាក់ក្នុងឆ្នាំ២០១១។

តាមរយៈប្រព័ន្ធព័ត៌មានជនរងគ្រោះនិងគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោក ក្នុងព្រះរាជាណាចក្រកម្ពុជា(Cambodia Road Crash and Victim Information System-RCVIS) ក្នុងឆ្នាំ២០១១ មានជនរងគ្រោះថ្នាក់ចរាចរណ៍ចំនួន១៦ ៦៥៤នាក់។ ក្នុងចំណោមជនរងគ្រោះទាំងនោះមាន ១ ៩០៥នាក់បានបាត់បង់ជីវិតនិងរបួសធ្ងន់៥ ៨០៧នាក់ (គិតជាមធ្យមមានមនុស្សស្លាប់ច្រើនជាង៥នាក់និងរបួសធ្ងន់១៦នាក់ក្នុងមួយថ្ងៃ)។ ចំនួនអ្នកស្លាប់បានកើនឡើងចំនួន៥%ធៀបនឹងឆ្នាំ២០១០។ អ្នកស្លាប់ភាគច្រើនជាអ្នកជិះម៉ូតូមាន៦៧% បន្ទាប់មក អ្នកថ្មើរជើង១៣% និងអ្នកជិះរថយន្តគ្រួសារ៧%។ បន្ថែមពីលើនេះ៦៥%នៃអ្នកស្លាប់ដែលជិះម៉ូតូ មានការប៉ះទង្គិចក្បាលពេលមានគ្រោះថ្នាក់។

ការបើកបរហួសល្បឿនកំណត់ជាមូលហេតុចម្បងនៃគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោកក្នុងព្រះរាជាណាចក្រកម្ពុជា។ អ្នកស្លាប់ច្រើនជាង៥០% ដោយសារការបើកបរហួសល្បឿនកំណត់ ១៥% ដោយសារការបើកបរក្រោមឥទ្ធិពលជាតិស្រវឹងនិងកត្តាផ្សេងៗទៀត។ ជនរងគ្រោះ៥៥%នៃអ្នកស្លាប់សរុប មានអាយុចន្លោះពី១៥-២៩ឆ្នាំ ហើយជាពិសេស ភាគរយខ្ពស់បំផុតនៃអ្នកស្លាប់មានអាយុចន្លោះពី២០-២៤ឆ្នាំ មាន២៤%។

ទំនោរផ្សេងទៀតនៃគ្រោះថ្នាក់ចរាចរណ៍នាពេលបច្ចុប្បន្ន យើងសង្កេតឃើញថាមានការប្រែប្រួលពីកើតឡើងភាគច្រើនលើផ្លូវជាតិទៅកើតឡើងលើផ្លូវខេត្តឬផ្លូវជនបទ និងពីក្នុងរាជធានីទៅទីរួមខេត្ត។ អត្រាស្លាប់តាមផ្លូវខេត្តឬផ្លូវជនបទ បានកើនឡើងពីចំនួន៤១%នៅឆ្នាំ២០០៦ទៅ៥១% នៅឆ្នាំ២០១០។ ក្នុងនោះអត្រាស្លាប់ក្នុងរាជធានីភ្នំពេញមានចំនួន០,៩៧% និងខេត្តសៀមរាបមានចំនួន១,៨៩%។

គ្រោះថ្នាក់ចរាចរណ៍បានធ្វើឲ្យប្រទេសកម្ពុជាយើង ខាតបង់ថវិកាអស់ជាច្រើនលានដុល្លារសហរដ្ឋអាមេរិកក្នុងមួយឆ្នាំៗ។ នេះមិនទាន់គិតដល់ផលវិបាកសង្គម ដូចជាការបន្សល់ទុកនូវកុមារកំព្រា ស្ត្រីមេម៉ាយ ជនពិការ និងទុរគតជន ដែលប៉ះពាល់ដល់គោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល។

# ២- ចក្ខុវិស័យ

គោលនយោបាយនេះមានចក្ខុវិស័យកាត់បន្ថយជាអតិបរមានូវគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោក ដើម្បីបញ្ចៀសនូវការស្លាប់ របួស ពិការភាព ការខូចខាតទ្រព្យសម្បត្តិ និងការប៉ះពាល់ដល់បរិស្ថានក្នុងព្រះរាជាណាចក្រកម្ពុជា។

# ៣- គោលបំណងនិងគោលដៅ

### ៣.១- គោលបំណង

គោលនយោបាយនេះមានគោលបំណងដូចតទៅ៖

- ធានាសុវត្ថិភាព សណ្ដាប់ធ្នាប់ចរាចរណ៍ផ្លូវគោក
- ទប់ស្កាត់ការប៉ះពាល់សុខភាព អាយុជីវិតមនុស្ស សត្វ ទ្រព្យសម្បត្តិ និងបរិស្ថាន។

### ៣.២- គោលដៅ

គោលនយោបាយនេះមានគោលដៅដូចតទៅ៖

- បង្កើនការយល់ដឹងអំពីសុវត្ថិភាពចរាចរណ៍ផ្លូវគោក
- បង្កើនប្រសិទ្ធភាពនៃការអនុវត្តច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោក
- បង្កើនសុវត្ថិភាពហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់
- បង្កើនសុវត្ថិភាពយានយន្ត
- បង្កើនប្រសិទ្ធភាពសេវាសង្គ្រោះ។

# ៤- យុទ្ធសាស្ត្រ

### ៤.១- ការអប់រំនិងការផ្សព្វផ្សាយ

- រៀបចំបញ្ចូលក្នុងកម្មវិធីសិក្សាស្ដីពីសុវត្ថិភាពចរាចរណ៍ផ្លូវគោក នៅកម្រិតមធ្យមសិក្សាទុតិយភូមិនៅក្នុងប្រព័ន្ធអប់រំ
- បង្កើនកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍ សង្គមស៊ីវិល និងវិស័យឯកជន ដើម្បីរៀបចំយុទ្ធនាការសុវត្ថិភាពចរាចរណ៍ផ្លូវគោក ដល់អ្នកប្រើប្រាស់ផ្លូវថ្នល់ដែលងាយរងគ្រោះនិងមានឥរិយាបថដែលនាំទៅរកគ្រោះថ្នាក់ចរាចរណ៍
- ជំរុញការផ្សព្វផ្សាយនិងការលើកកម្ពស់ការយល់ដឹងច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោក
- ជំរុញការផ្សព្វផ្សាយនិងអប់រំសុវត្ថិភាពចរាចរណ៍នៅតាមផ្លូវថ្នល់និងនៅតាមសហគមន៍ក្នុងព្រះរាជាណាចក្រកម្ពុជា។

### ៤.២- ការពង្រឹងការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្ត

- កសាងផែនការសកម្មភាពដើម្បីប្រតិបត្តិច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោក
- ពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់
- ជំរុញការយល់ដឹងច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោកដល់អ្នកប្រើប្រាស់ផ្លូវថ្នល់
- រឹតបន្តឹងការអនុវត្តច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោកដែលនៅជាធរមាននាបច្ចុប្បន្ននិងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធវិស័យចរាចរណ៍ ៨

- កសាងច្បាប់ថ្មី ស្តីពីចរាចរណ៍ផ្លូវគោកនិងកសាងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធវិស័យចរាចរណ៍ ក្នុងករណីចាំបាច់។

## ៤.៣- ការយកចិត្តទុកដាក់លើអ្នកប្រើប្រាស់ផ្លូវថ្នល់ដែលងាយរងគ្រោះថ្នាក់

- រៀបចំយុទ្ធនាការអប់រំនិងបណ្តុះបណ្តាលដល់អ្នកបើកបរទោចក្រយានយន្ត ត្រីចក្រយានយន្ត ដើម្បីជំរុញឲ្យមានឥរិយាបថបើកបរប្រកបដោយសុវត្ថិភាព
- បញ្ចូលក្នុងកម្មវិធីសិក្សារបស់សាលាបង្រៀនបើកបរយានយន្តអំពីសុវត្ថិភាពចរាចរណ៍ផ្លូវគោក ក្នុងបំណងបណ្តុះបណ្តាលអ្នកបើកបរទាំងអស់ឲ្យប្រកាន់យកឥរិយាបថបើកបរប្រកបដោយសុវត្ថិភាព គោរពសញ្ញាចរាចរណ៍ ច្បាប់ និងបទប្បញ្ញត្តិចរាចរណ៍នានា
- បង្កើតបរិយាកាសសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់កុមារតូចៗនិងអ្នកថ្មើរជើងនៅតំបន់ដែលពុំសូវមានសុវត្ថិភាព
- ពង្រឹងការអនុវត្តផែនការសកម្មភាពស្តីពីការពាក់មួកសុវត្ថិភាព។

## ៤.៤- ការពង្រឹងផ្នែកវិស្វកម្មសុវត្ថិភាពផ្លូវថ្នល់

- ត្រូវធ្វើសវនកម្មសុវត្ថិភាពផ្លូវថ្នល់ ដើម្បីបង្ការនិងកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍
- តម្រូវឲ្យមានវិធានការត្រួតពិនិត្យនៅរាល់ការដ្ឋានស្ពាននិងការដ្ឋានស្ថាបនាផ្លូវ ស្ពានថ្មី ដើម្បីសុវត្ថិភាពដល់អ្នកប្រើប្រាស់ផ្លូវថ្នល់
- កែលម្អកន្លែងដែលបានស្រាវជ្រាវរកឃើញថាមានគ្រោះថ្នាក់ញឹកញាប់
- ពង្រឹងការបំពាក់និងការថែទាំបរិក្ខារសុវត្ថិភាពចរាចរណ៍នៅតាមផ្លូវថ្នល់ឲ្យបានសមស្របតាមនិយាមបច្ចេកទេសដែលបានកំណត់និងតាមតម្រូវ។

## ៤.៥- ការពង្រឹងប្រសិទ្ធភាពនៃសេវាសង្គ្រោះបឋមនិងសង្គ្រោះបន្ទាន់

- ជំរុញកិច្ចសហការរវាងក្រសួង ស្ថាប័នមានសមត្ថកិច្ចជាមួយបណ្តាអង្គការមិនមែនរដ្ឋាភិបាលនិងវិស័យឯកជននានាដើម្បីបង្កើតនូវប្រព័ន្ធសង្គ្រោះបឋមនិងសង្គ្រោះបន្ទាន់
- ពង្រឹងការបណ្តុះបណ្តាលនូវវិធីសង្គ្រោះបន្ទាន់ដល់បុគ្គលិកសុខាភិបាល
- ពង្រឹងការបណ្តុះបណ្តាលនូវវិធីសង្គ្រោះបឋមដល់ភ្នាក់ងារមានសមត្ថកិច្ច អ្នកបើកបរ និងអ្នកស្ម័គ្រចិត្តនានា
- លើកទឹកចិត្តឲ្យមានការបង្កើតប្រព័ន្ធប្រសិទ្ធភាពសេវាដឹកជញ្ជូនសង្គ្រោះបន្ទាន់ ដើម្បីជួយសង្គ្រោះនិងថែទាំដល់ជនរងគ្រោះ
- ជំរុញសេវាផ្តល់ព័ត៌មានអំពីចរាចរណ៍និងគ្រោះថ្នាក់ចរាចរណ៍។

## ៤.៦- ពង្រឹងការបណ្តុះបណ្តាលអ្នកបើកបរនិងការត្រួតពិនិត្យយានយន្ត

- ពង្រឹងគុណភាពនៃការបណ្តុះបណ្តាលនៅតាមសាលាបង្រៀនបើកបរ ការប្រឡងយកបណ្ណបើកបរ និងការគ្រប់គ្រងប្រព័ន្ធផ្តល់បណ្ណបើកបរយានយន្ត
- ពង្រឹងគុណភាពការត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្ត ឲ្យបានសមស្របតាមនិយាមបច្ចេកទេស។

៤.៧- ពង្រឹងការគ្រប់គ្រងទិន្នន័យនិងការស្រាវជ្រាវគ្រោះថ្នាក់ចរាចរណ៍

- ពង្រឹងការគ្រប់គ្រងប្រព័ន្ធព័ត៌មានជនរងគ្រោះនិងគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោក
- ពង្រឹងការប្រមូលព័ត៌មានគ្រោះថ្នាក់ចរាចរណ៍ឲ្យកាន់តែសុក្រឹត
- ជំរុញការសិក្សាស្រាវជ្រាវនិងការវិភាគអំពីមូលហេតុគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោក និងការកសាងវិធានការសុវត្ថិភាពចរាចរណ៍ផ្លូវគោកនាពេលអនាគត។

៤.៨- ពង្រឹងការគ្រប់គ្រងទៅលើសុវត្ថិភាពដឹកជញ្ជូនអ្នកដំណើរនិងទំនិញ

- ជំរុញនិងលើកទឹកចិត្តដល់អ្នកប្រកបរបរដឹកជញ្ជូនឲ្យបង្កើតក្រុមហ៊ុនដឹកជញ្ជូននិងចូលរួមក្នុងសមាគមដឹកជញ្ជូនអ្នកដំណើរឬទំនិញ
- កសាងឯកសារណែនាំនិងផ្សព្វផ្សាយស្តីពីការគ្រប់គ្រងសុវត្ថិភាពក្នុងការដឹកជញ្ជូនអ្នកដំណើរនិងទំនិញ
- តាមដាន ត្រួតពិនិត្យ វាយតម្លៃទៅលើសុវត្ថិភាពក្នុងការដឹកជញ្ជូនអ្នកដំណើរនិងទំនិញ។

## ៥- ផែនការសកម្មភាព

### ៥.១- យន្តការអនុវត្ត

គណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក មានភារកិច្ចសំខាន់ៗ ដូចខាងក្រោម៖

- ពង្រឹងរចនាសម្ព័ន្ធគ្រប់គ្រងសុវត្ថិភាពចរាចរណ៍ផ្លូវគោក ចាប់ពីថ្នាក់ជាតិរហូតដល់ថ្នាក់មូលដ្ឋាន
- ពង្រឹងយន្តការហិរញ្ញវត្ថុសម្រាប់ទ្រទ្រង់ដល់សកម្មភាពសុវត្ថិភាពចរាចរណ៍ផ្លូវគោក
- បណ្តុះបណ្តាលជំនាញផ្នែកសុវត្ថិភាពចរាចរណ៍ផ្លូវគោក
- បង្កើតភាពជាដៃគូនិងសហការជាមួយដៃគូអភិវឌ្ឍ សង្គមស៊ីវិល និងវិស័យឯកជនដើម្បីអនុវត្តកម្មវិធីសុវត្ថិភាពចរាចរណ៍ផ្លូវគោក។

### ៥.២- ការបង្កើតក្របខ័ណ្ឌគតិយុត្ត

- រៀបចំលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីអនុវត្តច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក
- ធ្វើវិសោធនកម្មច្បាប់ចរាចរណ៍ផ្លូវគោក លើចំណុចសំខាន់ៗ
- រៀបចំសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក ។

### ៥.៣- ការគាំទ្រហិរញ្ញវត្ថុ

ថវិកាសម្រាប់ទ្រទ្រង់ការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោក បានមកពី៖

- ថវិកាជាតិជាមូលដ្ឋាន
- ថវិកាបានមកពីប្រភពផ្សេងៗទៀត។

**៥.៤- ការបណ្ដុះបណ្ដាលធនធានមនុស្ស**

ដើម្បីពង្រឹងប្រសិទ្ធភាពការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោក ត្រូវផ្ដោតលើការបណ្ដុះបណ្ដាលដល់៖

- មន្ត្រីនៃគណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក
- មន្ត្រីនៃស្ថាប័នពាក់ព័ន្ធទាំងអស់។

**៥.៥- ដំណើរការអនុវត្តគម្រោង**

ដើម្បីអនុវត្តគម្រោងសុវត្ថិភាពចរាចរណ៍ផ្លូវគោកឆ្នាំ២០១១-២០២០ ត្រូវកសាងផែនការសកម្មភាពជាតិស្របតាមផែនការទសវត្សរ៍សកម្មភាពសុវត្ថិភាពចរាចរណ៍ផ្លូវគោករបស់អង្គការសហប្រជាជាតិ២០១១-២០២០។

ផែនការសកម្មភាពជាតិទសវត្សរ៍សុវត្ថិភាពចរាចរណ៍ផ្លូវគោកឆ្នាំ២០១១-២០២០ មានសកម្មភាពដូចខាងក្រោម៖

សកម្មភាពទី១- ការគ្រប់គ្រងសុវត្ថិភាពចរាចរណ៍
សកម្មភាពទី២- សុវត្ថិភាពហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់
សកម្មភាពទី៣- សុវត្ថិភាពយានយន្ត
សកម្មភាពទី៤- អាកប្បកិរិយាប្រកបដោយសុវត្ថិភាពរបស់អ្នកប្រើប្រាស់ផ្លូវថ្នល់
សកម្មភាពទី៥- ប្រព័ន្ធសង្គ្រោះបន្ទាន់វេជ្ជសាស្ត្រ
សកម្មភាពទី៦- វិសោធនកម្មច្បាប់និងពង្រឹងការអនុវត្តច្បាប់
សកម្មភាពទី៧- បណ្ណបើកបរ
សកម្មភាពទី៨- ការគ្រប់គ្រងនិងវាយតម្លៃទៅលើសុវត្ថិភាពដឹកជញ្ជូនអ្នកដំណើរនិងទំនិញ។

**សកម្មភាពទី១- ការគ្រប់គ្រងសុវត្ថិភាពចរាចរណ៍**

សុវត្ថិភាពចរាចរណ៍គឺជាបញ្ហាពហុវិស័យ ដូច្នេះ ទាមទារនូវប្រព័ន្ធគ្រប់គ្រងមួយដែលមានលក្ខណៈពហុវិស័យដូចគ្នា ដើម្បីអនុញ្ញាតឲ្យស្ថាប័នពាក់ព័ន្ធទាំងឡាយធ្វើការកសាងនិងអនុវត្តយុទ្ធសាស្ត្រ គោលនយោបាយ និងផែនការឲ្យបានសមស្រប ព្រមទាំងដើម្បីធ្វើការសម្របសម្រួលរវាងស្ថាប័នដែលចូលរួមអនុវត្តគ្រប់ជាន់ថ្នាក់ក្នុងវិស័យសុវត្ថិភាពចរាចរណ៍។

ផែនការនេះនឹងផ្ដោតការយកចិត្តទុកដាក់ធានាឲ្យមានការឧបត្ថម្ភផ្នែកហិរញ្ញវត្ថុឲ្យបានគ្រប់គ្រាន់ ដើម្បីសម្រេចឲ្យបានជោគជ័យនូវគោលដៅនិងទិសដៅនៃផែនការ ក៏ដូចជាធានាឲ្យមានការអភិវឌ្ឍជំនាញបច្ចេកទេសនិងសមត្ថភាពដែលជាតម្រូវការចាំបាច់ ក្នុងចំណោមមន្ត្រីបម្រើការងារផ្នែកសុវត្ថិភាពចរាចរណ៍ក្នុងការអនុវត្តផែនការសកម្មភាពឲ្យទទួលបានជោគជ័យ។ អាទិភាពចម្បងនឹងត្រូវធ្វើឲ្យប្រសើរឡើងនូវគុណភាពនៃប្រព័ន្ធព័ត៌មានជនរងគ្រោះនិងគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោក(RCVIS) និងត្រូវច្របាច់បញ្ចូលគ្នានូវទិន្នន័យដែលទទួលបានពីថ្នាក់រាជធានី ខេត្ត។ ពេលនោះ ការសិក្សាស្រាវជ្រាវនឹងត្រូវរៀបចំឡើងជាបន្តបន្ទាប់។ ការអនុវត្តផែនការនេះនឹងត្រូវធ្វើការតាមដាន ព្រមទាំងវាយតម្លៃឲ្យបានដិតដល់ ដើម្បីធានាថាយើងសម្រេចបាននូវគោលដៅតាមផែនការដែលបានគ្រោងទុក។ គណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក(**គ.ស.ច.គ.**) មានភារកិច្ចគ្រប់គ្រង តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

សម្របសម្រួលនិងសហការប្រកបដោយភាពរលូន ដើម្បីធានា សម្រេចបានគោលដៅផែនការដែលបានគ្រោងទុក។

បន្ថែមលើនេះ មជ្ឈមណ្ឌលធ្វើតេស្តមួកសុវត្ថិភាព ត្រូវបានបង្កើតឡើងដើម្បីធ្វើតេស្តស្តង់ដាមួកសុវត្ថិភាពដែលដាក់លក់លើទីផ្សារទាំងអស់។

## សកម្មភាពទី២- សុវត្ថិភាពហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់

ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់កំពុងដើរតួនាទីយ៉ាងសំខាន់ក្នុងវិស័យសុវត្ថិភាពចរាចរណ៍។ ផ្លូវថ្នល់ដែលមានគុណភាពនិងសុវត្ថិភាព គឺអាចជួយឲ្យប្រជាជនធ្វើដំណើរមានសុវត្ថិភាព និងអាចកាត់បន្ថយជាអតិបរមានូវហានិភ័យដែលអាចកើតឡើង ដោយពង្រឹងការបំពាក់គ្រឿងបរិក្ខារនិងបំពាក់បន្ថែមនូវសំណង់សិល្បការផ្សេងៗដែលការពារសុវត្ថិភាពចរាចរណ៍ អនុលោមទៅតាមនិយាមបច្ចេកទេសនិងតម្រូវការជាក់ស្តែង។ ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ត្រូវផ្តោតជាសំខាន់ទៅលើលក្ខណៈអនុគ្រោះចំពោះអ្នកប្រើប្រាស់ផ្លូវថ្នល់ដែលងាយរងគ្រោះ(ដូចជាអ្នកបើកបរទោចក្រយានយន្តនិងត្រីចក្រយានយន្ត ថ្មើរជើង កុមារ និងជនពិការ)។

ផែនការនេះនឹងផ្តោតការយកចិត្តទុកដាក់ទៅលើដំណោះស្រាយផ្នែកវិស្វកម្ម ដែលនាំទៅរកការកាត់បន្ថយល្បឿនយានយន្តតាមរយៈវិធានការ "ការកាត់បន្ថយល្បឿន" និងការគ្រប់គ្រងល្បឿន ពិសេស នៅក្នុងតំបន់ដែលមានអ្នកប្រើប្រាស់ផ្លូវដែលងាយរងគ្រោះឆ្លងកាត់កន្លែងកុះករ ដូចជា តំបន់សាលារៀន តំបន់មានលំនៅឋាន និងតំបន់ទីប្រជុំជន។ កម្មវិធីកែលម្អតំបន់មានគ្រោះថ្នាក់ញឹកញាប់និងកម្មវិធីសវនកម្មសុវត្ថិភាពចរាចរណ៍នឹងត្រូវអនុវត្តតាមផ្លូវគោក។ វិស្វករផ្នែកស្ពានថ្នល់នឹងត្រូវទទួលការបណ្តុះបណ្តាលស្តីពីបច្ចេកទេសសវនកម្មផ្លូវ ហើយអាទិភាពនឹងត្រូវផ្តោតទៅលើសមាហរណកម្មសវនកម្ម បញ្ចូលទៅក្នុងគម្រោងរចនាផ្លូវថ្នល់និងគម្រោងហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់។

## សកម្មភាពទី៣- សុវត្ថិភាពយានយន្ត

ការកែលម្អលើលក្ខណៈបច្ចេកទេសការពារគ្រោះថ្នាក់ចរាចរណ៍និងសុវត្ថិភាពដែលបំពាក់ក្នុងរថយន្តអាចជួយកាត់បន្ថយការរងរបួសធ្ងន់ធ្ងរ ការស្លាប់បាត់បង់បាន។ ដូចនេះ ការផ្តោតលើការពង្រឹងគុណភាពត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្តឲ្យមានសុវត្ថិភាពនិងការទប់ស្កាត់ការនាំចូលនិងការកែច្នៃយានយន្តដែលខុសបទដ្ឋានលក្ខណៈបច្ចេកទេសគឺជាបញ្ហាសំខាន់។ ផែនការនេះបានអំពាវនាវឲ្យមានការកែលម្អនិងពង្រីកសុវត្ថិភាពក្នុងការដឹកជញ្ជូន ពិសេស ក្នុងចំណោមក្រុមហ៊ុន អង្គការ និងស្ថាប័នរដ្ឋាភិបាល។ កម្មវិធីត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្តនិងត្រូវទទួលការកែលម្អនិងពង្រីកបន្ថែមទៀតសម្រាប់ត្រួតពិនិត្យយានយន្តគ្រប់ប្រភេទ។ ចំពោះជនពិការ ផែនការនេះនឹងធ្វើការវាយតម្លៃទៅលើពួកគេនិងខិតខំឲ្យបានផុលផុសក្នុងការបង្កើតកម្មវិធីច្នៃយានយន្តសម្រាប់ជនពិការដើម្បីឲ្យពួកគេមានលទ្ធភាពធ្វើដំណើរប្រកបដោយសុវត្ថិភាព ក្នុងព្រះរាជាណាចក្រកម្ពុជា។

## សកម្មភាពទី៤- អាកប្បកិរិយាប្រកបដោយសុវត្ថិភាពរបស់អ្នកប្រើប្រាស់ផ្លូវថ្នល់

អ្នកប្រើប្រាស់ផ្លូវថ្នល់គ្រប់រូបមានការទទួលខុសត្រូវរួមក្នុងការប្រើប្រាស់ផ្លូវថ្នល់ប្រកបដោយសុវត្ថិភាព ព្រមទាំងយកចិត្តទុកដាក់ទៅដល់អ្នកប្រើប្រាស់ផ្លូវថ្នល់ផ្សេងទៀត។ ដើម្បីកែប្រែឥរិយាបថរបស់អ្នកប្រើប្រាស់ផ្លូវថ្នល់មួយចំនួននិងដើម្បីការពារអ្នកប្រើប្រាស់ផ្លូវថ្នល់ដែលងាយ

រងគ្រោះ យើងត្រូវតែបង្កើនការយល់ដឹងនិងផ្លាស់ប្តូរឥរិយាបថរបស់ប្រជាជនដែលកំពុងតែប្រើប្រាស់ផ្លូវថ្នល់។ យើងពិតជាអាចកាត់បន្ថយកត្តាហានិភ័យដែលបង្កឲ្យមានគ្រោះថ្នាក់ចរាចរណ៍និងជនរងគ្រោះឲ្យស្ថិតនៅកម្រិតអប្បបរមាបានតាមរយៈការអប់រំឥរិយាបថសុវត្ថិភាព។

ផែនការនេះផ្តោតទៅលើកត្តាហានិភ័យចម្បងៗដែលបានរកឃើញនៅក្នុងប្រព័ន្ធព័ត៌មានជនរងគ្រោះនិងគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោក(Cambodia Road Crash and Victim Information System-RCVIS) ដូចជា ការមិនពាក់មួកសុវត្ថិភាព ការបើកបរហួសល្បឿនកំណត់ ការបើកបរក្រោមឥទ្ធិពលជាតិស្រវឹង ការមិនប្រើប្រាស់ខ្សែក្រវាត់សុវត្ថិភាពនិងខ្សែក្រវាត់សុវត្ថិភាពសម្រាប់កុមារ ការផ្ទុកលើសចំណុះ និងគ្មានបណ្ណបើកបរ។ យុទ្ធសាស្ត្ររបស់យើងនឹងផ្សារភ្ជាប់ជាមួយការផ្សព្វផ្សាយអប់រំសាធារណៈតាមរយៈប្រព័ន្ធផ្សព្វផ្សាយនានា កម្មវិធីអប់រំតាមសាលារៀននិងសាកលវិទ្យាល័យស្តីពីសុវត្ថិភាពចរាចរណ៍ មិត្តអប់រំមិត្តនិងវិធីសាស្ត្រផ្សេងៗទៀត។ យុទ្ធនាការអប់រំផ្សព្វផ្សាយភាគច្រើននឹងត្រូវធ្វើឡើង ដោយផ្សារភ្ជាប់ជាមួយនឹងការពង្រឹងការអនុវត្តច្បាប់ដើម្បីទទួលបានលទ្ធផលកម្រិតអតិបរមា។

ផែនការនេះផ្តោតទៅលើកត្តាហានិភ័យដែលមានចំពោះអ្នកប្រើប្រាស់ផ្លូវដែលងាយរងគ្រោះ។ គម្រោងសុវត្ថិភាពចរាចរណ៍នៅតំបន់សាលារៀននឹងត្រូវបានបង្កើតឡើងសម្រាប់ឲ្យកុមារឆ្លងកាត់នៅត្រង់កន្លែងឆ្លងកាត់ផ្លូវមានសុវត្ថិភាពសម្រាប់អ្នកថ្មើរជើង ក៏ដូចជាតំបន់សម្រាប់តែអ្នកថ្មើរជើងធ្វើដំណើរ។ អ្នកបើកបរនិងអ្នករួមដំណើរតាមទោចក្រយាន ទោចក្រយានយន្ត ត្រីចក្រយាន និងត្រីចក្រយានយន្តនឹងត្រូវបានផ្តោតការយកចិត្តទុកដាក់ ពិសេស ការពាក់មួកសុវត្ថិភាព ការអប់រំ ការផ្សព្វផ្សាយ និងការអនុវត្តច្បាប់ស្តីពីស្លៀកពាក់មួកសុវត្ថិភាព ការបណ្តុះបណ្តាល និងការផ្តល់បណ្ណបើកបរ។

## សកម្មភាពទី៥- ប្រព័ន្ធសង្គ្រោះបន្ទាន់វេជ្ជសាស្ត្រ

ការសង្គ្រោះបន្ទាន់វេជ្ជសាស្ត្របានគ្របដណ្តប់ស្ថានភាពធំៗជាច្រើនដែលមានដូចជាការសង្គ្រោះបន្ទាន់វេជ្ជសាស្ត្រ ក្នុងផ្នែករបួសគ្រាំគ្រាជាដើម។ ក្រសួងសុខាភិបាលនឹងជំរុញការកែលម្អប្រព័ន្ធសេវាសង្គ្រោះបន្ទាន់វេជ្ជសាស្ត្រមូលដ្ឋាននៅទូទាំងប្រទេស ដើម្បីផ្តល់សេវាថែទាំអ្នករងគ្រោះឲ្យបានទាន់ពេលមុនបញ្ជូនដល់មន្ទីរពេទ្យនិងដើម្បីដឹកអ្នករងគ្រោះប្រកបដោយសុវត្ថិភាពទៅកាន់មន្ទីរពេទ្យសមស្របណាមួយ។ ផ្នែកសង្គ្រោះបន្ទាន់របស់មន្ទីរពេទ្យ គឺជាសមាសភាគមួយដ៏ពេញលេញនៃប្រព័ន្ធសេវាសង្គ្រោះបន្ទាន់វេជ្ជសាស្ត្រ។ ប្រព័ន្ធសេវាសង្គ្រោះបន្ទាន់វេជ្ជសាស្ត្រនេះបានបង្កើតឡើងផងដែរជាមួយនឹងទស្សនៈមួយដើម្បីផ្តល់នូវការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពនូវជនរងគ្រោះដោយឧប្បត្តិហេតុ។ ក្រសួងសុខាភិបាលបានកំណត់គោលនយោបាយជាតិស្តីពីការថែទាំអ្នកជំងឺមុនពេលបញ្ជូនមកដល់និងពេលមកដល់មន្ទីរពេទ្យ។

## សកម្មភាពទី៦- វិសោធនកម្មច្បាប់និងការពង្រឹងការអនុវត្តច្បាប់

ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកបានផ្តល់នូវក្របខ័ណ្ឌការងារដល់នគរបាលចរាចរណ៍និងស្ថាប័នផ្សេងៗទៀតដែលទទួលភារកិច្ចអនុវត្តច្បាប់នេះដើម្បីបង្កើនប្រសិទ្ធភាពការអនុវត្តច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។ ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកនេះត្រូវតែជំរុញឲ្យតែបន្តឹងអនុវត្ត [illegible] រលឹមនិងប្រកបដោយនិរន្តរភាពសំដៅទប់ស្កាត់កត្តាហានិភ័យចម្បងៗ។ ការអនុវត្តច្បាប់ស្តីពី

ចរាចរណ៍ផ្លូវគោកមានប្រសិទ្ធភាព និងអាចផ្លាស់ប្តូរឥរិយាបថរបស់អ្នកប្រើប្រាស់ផ្លូវនិងកាត់បន្ថយគ្រោះថ្នាក់និងជនរងគ្រោះជាក់ជាមិនខាន។

នៅក្នុងផែនការនេះ ការពង្រឹងការអនុវត្តច្បាប់នឹងផ្តោតទៅលើកត្តាហានិភ័យចម្បងៗស្តីពីគ្រោះថ្នាក់និងជនរងគ្រោះដោយគ្រោះថ្នាក់ចរាចរណ៍ ជាគោលដៅដែលឆ្លងតាមការវិភាគចេញពីប្រព័ន្ធRCVIS។ កត្តាទាំងនោះមានដូចជា ការមិនពាក់មួកសុវត្ថិភាព ការបើកបរហួសល្បឿនកំណត់ ការបើកបរក្រោមឥទ្ធិពលជាតិស្រវឹង ការមិនប្រើប្រាស់ខ្សែក្រវាត់សុវត្ថិភាពនិងខ្សែក្រវាត់សុវត្ថិភាពសម្រាប់កុមារ ការផ្ទុកលើសចំណុះ ការបើកបរដោយគ្មានបណ្ណបើកបរ។ល។ ផែនការនេះនឹងត្រូវធានាផងដែរថា នគរបាលចរាចរណ៍នឹងទទួលបានការកសាងសមត្ថភាពសមស្រប បំពាក់ឧបករណ៍ហ៊ឹកហ្វឺនបណ្តុះបណ្តាលនិងអភិវឌ្ឍជំនាញវិជ្ជាជីវៈ និងច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកនឹងត្រូវបន្តធ្វើវិសោធនកម្មបន្ថែមទៀតតាមការចាំបាច់ ដើម្បីឆ្លើយតបទៅតាមស្ថានភាពជាក់ស្តែង។

**សកម្មភាពទី៧- បណ្ណបើកបរ**

បណ្ណបើកបរគឺជាផ្នែកមួយដ៏មានសារៈសំខាន់និងជាមូលដ្ឋានចំពោះអ្នកបើកបរយានយន្តគ្រប់ប្រភេទ។ ផែនការនេះផ្តោតទៅលើការពង្រឹងគុណភាពនៃការរៀន ការបង្រៀននៅតាមសាលាបង្រៀនបើកបរ និងសមត្ថភាពគ្រូបង្រៀនបើកបរ។ មេរៀនសម្រាប់បង្ហាត់បង្រៀនច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកនិងផ្នែកដៃចង្កូតយានយន្ត ត្រូវស្របទៅតាមនិយាមអន្តរជាតិ។ ប្រព័ន្ធទិន្នន័យស្តីពីការផ្តល់បណ្ណបើកបរនៃនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក នឹងត្រូវផ្សារភ្ជាប់ជាមួយនឹងប្រព័ន្ធរបស់នគរបាលនិងតុលាការដើម្បីធ្វើឲ្យការពង្រឹងការអនុវត្តច្បាប់ទទួលបានប្រសិទ្ធភាពថែមមួយកម្រិតទៀត។ ក្នុងនោះ យើងនឹងបង្កើតប្រព័ន្ធដកពិន្ទុបណ្ណបើកបរផងដែរ។

**សកម្មភាពទី៨- ការគ្រប់គ្រងនិងវាយតម្លៃទៅលើសុវត្ថិភាពដឹកជញ្ជូនអ្នកដំណើរនិងទំនិញ**

ការគ្រប់គ្រងនិងវាយតម្លៃសុវត្ថិភាពចរាចរណ៍ក្នុងការដឹកជញ្ជូន ជាវិធានការកែលម្អជាប់ជាប្រចាំនូវសុវត្ថិភាពដឹកជញ្ជូនអ្នកដំណើរនិងទំនិញ ដើម្បីធានាបាននូវសុវត្ថិភាពអាចជឿទុកចិត្តបាន។

**តារាងសកម្មភាពទាំង៨**

| ល.រ. | សកម្មភាព | ដំណើរការ |
|---|---|---|
| ១ | ការគ្រប់គ្រងសុវត្ថិភាពចរាចរណ៍ | - ការកសាងសមត្ថភាពមន្ត្រីតាមរយៈការរៀបចំវគ្គបណ្តុះបណ្តាល កម្មវិធីផ្លាស់ប្តូរបទពិសោធ និងទស្សនកិច្ចសិក្សា<br>- ការផ្តល់ថវិកានិងធនធានតាមរយៈការកំណត់ផែនការប្រចាំឆ្នាំរបស់រាជរដ្ឋាភិបាលនិងកិច្ចសហការជាមួយដៃគូអភិវឌ្ឍនានា<br>- ការពង្រីកនូវការប្រើប្រាស់ប្រព័ន្ធទិន្នន័យនិងព័ត៌មានគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោកតាមបណ្តារាជធានី ខេត្ត<br>- ការបង្កើតមជ្ឈមណ្ឌលស្រាវជ្រាវ កត្តាហានិភ័យ និងការខាតបង់សេដ្ឋកិច្ច ដើម្បី |

| | | |
|---|---|---|
| | | ធ្វើការវាយតម្លៃលើសកម្មភាពអាទិភាពដែលពាក់ព័ន្ធ<br>- ការបង្កើតយុទ្ធនាការអប់រំដល់អ្នកប្រើប្រាស់ផ្លូវដែលងាយរងគ្រោះ (ថ្មើរជើង កង់ ម៉ូតូ)<br>- ធ្វើការតាមដាននិងការវាយតម្លៃការអនុវត្តផែនការសកម្មភាពជាតិទសវត្សរ៍សុវត្ថិភាពចរាចរណ៍ផ្លូវគោកនៅពាក់កណ្តាលផែនការសកម្មភាព<br>- ការពង្រឹងយន្តការសម្របសម្រួល សហប្រតិបត្តិការជាមួយដៃគូ ស្ថាប័នពាក់ព័ន្ធថ្នាក់ជាតិ តំបន់ និងអន្តរជាតិ តាមរយៈការរៀបចំកិច្ចប្រជុំ។ |
| ២ | សុវត្ថិភាពហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ | - ធ្វើការវាយតម្លៃកន្លែងដែលមានគ្រោះថ្នាក់ញឹកញាប់និងដាក់វិធានការចាំបាច់ដើម្បីកែលម្អកន្លែងទាំងនោះឲ្យមានសុវត្ថិភាព<br>- អនុវត្តគម្រោងសាកល្បងជាបន្តបន្ទាប់ ដើម្បីកាត់បន្ថយល្បឿនលើសកំណត់ក្នុងទីប្រជុំជននិងក្រៅទីប្រជុំជនដែលមានគ្រោះថ្នាក់<br>- រៀបចំបំពាក់បរិក្ខារសុវត្ថិភាពចរាចរណ៍គ្រប់គ្រាន់ ពិសេស ផ្លាកសញ្ញាកំណត់ល្បឿននៅក្នុងតំបន់ដែលមានហានិភ័យខ្ពស់<br>- រៀបចំសេចក្តីណែនាំស្តីពីសវនកម្មនិងបំប៉នវិស្វករ អំពីវិធីសាស្ត្រក្នុងការធ្វើសវនកម្ម<br>- កសាងគន្លងផ្លូវដោយឡែកសម្រាប់ម៉ូតូ កង់ នៅតាមផ្លូវដែលបានជ្រើសរើសក្នុងទីក្រុងនិងផ្លូវជាតិ<br>- បង្កើតនិងកែលម្អប្រព័ន្ធដឹកជញ្ជូនសាធារណៈ ចម្រុះ និងស្តានីយចំណត<br>- រៀបចំសវនកម្មសុវត្ថិភាពចរាចរណ៍តាមវិធីសាស្ត្រសុវត្ថិភាព ដែលប្រកបដោយនិរន្តរភាពក្នុង៣ដំណាក់កាល គឺសិក្សាការសាងសង់ ដំណើរការសាងសង់ និងក្រោយការសាងសង់រួច។ |
| ៣ | សុវត្ថិភាពយានយន្ត | - បង្កើតប្រព័ន្ធស្តង់ដាបច្ចេកទេសសុវត្ថិភាពយានយន្តសម្រាប់យានយន្តនាំចូល និងផលិតក្នុងស្រុក<br>- លើកកម្ពស់ការយល់ដឹងក្នុងចំណោមអ្នកប្រើប្រាស់ អំពីសុវត្ថិភាពយានយន្ត<br>- បង្កើតបន្ថែមនិងកែលម្អមជ្ឈមណ្ឌលត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្តទាំង២៥ រាជធានី ខេត្ត ដោយផ្អែកលើស្តង់ដាសុវត្ថិភាពអន្តរជាតិ។ |
| ៤ | អាកប្បកិរិយាប្រកបដោយសុវត្ថិភាពរបស់អ្នកប្រើប្រាស់ផ្លូវថ្នល់ | - កសាងយុទ្ធសាស្ត្រអប់រំ ផ្សព្វផ្សាយសាធារណៈស្តីពីច្បាប់ចរាចរណ៍ផ្លូវគោក និងកសាងផែនការសកម្មភាពស្តីពីការអប់រំសុវត្ថិភាពចរាចរណ៍ដែលមានលក្ខណៈទូលំទូលាយ<br>- ធ្វើការអប់រំអ្នកបើកបរយានយន្តឲ្យយល់ដឹងពីគ្រោះថ្នាក់ដែលបណ្តាលមកពីការមិនពាក់មួកសុវត្ថិភាព ការបើកបរហួសល្បឿនកំណត់ ការបើកបរក្រោមឥទ្ធិពលជាតិស្រវឹង ការមិនពាក់ខ្សែក្រវាត់សុវត្ថិភាព ការផ្ទុកលើសទម្ងន់កំណត់<br>- បង្កើតផ្លូវសម្រាប់ថ្មើរជើងឆ្លងកាត់នៅតំបន់ទីប្រជុំជន<br>- អប់រំផ្សព្វផ្សាយដល់អ្នកប្រើប្រាស់ផ្លូវ រួមទាំងក្រុមហ៊ុនដឹកជញ្ជូនអំពីការធ្វើដំណើរ |

| | | |
|---|---|---|
| | | ប្រកបដោយសុវត្ថិភាព។ |
| ៥ | ប្រព័ន្ធសង្គ្រោះបន្ទាន់វេជ្ជសាស្ត្រ | - ជំរុញកែលម្អប្រព័ន្ធសង្គ្រោះបន្ទាន់បឋម មុនបញ្ជូនមកដល់មន្ទីរពេទ្យឬមណ្ឌលសុខភាព<br>- បំពាក់បំប៉ន កសាងសមត្ថភាពសម្រាប់នគរបាលចរាចរណ៍ កងរាជអាវុធហត្ថ និងសហគមន៍អំពីការសង្គ្រោះបន្ទាន់បឋម<br>- ពង្រឹងគុណភាពសង្គ្រោះនិងគ្រប់គ្រងអ្នករបួសក្នុងមន្ទីរពេទ្យ<br>- ជំរុញការកែលម្អនិងផ្សព្វផ្សាយប្រព័ន្ធទំនាក់ទំនងរបស់មជ្ឈមណ្ឌលទទួលព័ត៌មានគ្រោះថ្នាក់<br>- ពង្រឹងសេវារថយន្តសង្គ្រោះបន្ទាន់ ព្រមទាំងបំពាក់សម្ភារៈដែលមានស្តង់ដា និងធនធានមនុស្សមានសមត្ថភាព<br>- ជំរុញការប្រើប្រាស់ប្រព័ន្ធស្តារលទ្ធភាពពលកម្មសម្រាប់ជនរងគ្រោះដោយគ្រោះថ្នាក់ចរាចរណ៍។ |
| ៦ | វិសោធនកម្មច្បាប់និងពង្រឹងការអនុវត្តច្បាប់ | - ធ្វើវិសោធនកម្មច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក<br>- ត្រួតពិនិត្យឡើងវិញនូវការអនុវត្តច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកនិងផែនការសកម្មភាព<br>- ផ្តល់វគ្គបណ្តុះបណ្តាលស្តីពីការអនុវត្តច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកដល់មន្ត្រីមានសមត្ថកិច្ចនៃក្រសួង ស្ថាប័នពាក់ព័ន្ធ<br>- បំពាក់និងធ្វើទំនើបកម្មឧបករណ៍ មធ្យោបាយ និងសម្ភារៈអនុវត្តច្បាប់<br>- រឹតបន្តឹងការអនុវត្តច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកឲ្យបានម៉ឺងម៉ាត់ ជាអាទិ៍ រឹតបន្តឹងការពាក់មួកសុវត្ថិភាព ការបើកបរហួសល្បឿនកំណត់ និងការបើកបរក្រោមឥទ្ធិពលស្រវឹង។ |
| ៧ | បណ្ណបើកបរ | - ពង្រឹងគុណភាពនៃការបង្រៀនបើកបរយានយន្តនិងគុណភាពនៃការប្រឡងយកបណ្ណបើកបរយានយន្ត<br>- ជំរុញការបណ្តុះបណ្តាលអំពីបច្ចេកទេសបើកបរយានយន្តតាមប្រព័ន្ធកុំព្យូទ័រ (SIMULATOR) នៅតាមសាលាបង្រៀនបើកបរយានយន្ត<br>- ត្រួតពិនិត្យនិងបំប៉នជំនាញបន្ថែមលើការបើកបរយានយន្ត ដល់អ្នកបើកបររថយន្តធុនធំ<br>- ជំរុញការបណ្តុះបណ្តាលនិងចេញវិញ្ញាបនបត្របញ្ជាក់សមត្ថភាពដល់គ្រូបង្រៀនបើកបរនិងគណៈកម្មការប្រឡងយកបណ្ណបើកបរយានយន្ត<br>- ជំរុញឲ្យបង្កើតប្រព័ន្ធប្រឡងយកបណ្ណបើកបរតាមប្រព័ន្ធកុំព្យូទ័រនិងឧបករណ៍ស្វ័យប្រវត្ត នៅទូទាំងប្រទេស<br>- បង្កើតនិងអនុវត្តប្រព័ន្ធដកពិន្ទុលើបណ្ណបើកបរនិងការដកហូតបណ្ណបើកបរ<br>- ចេញបណ្ណបើកបរអន្តរជាតិឲ្យស្របតាមនិយាមអន្តរជាតិ |

| | | |
|---|---|---|
| | | - ចេញបណ្ណបើកបរដល់ជនពិការក្នុងករណីពិសេស<br>- ជំរុញការប្រឡងយកបណ្ណបើកបរទោចក្រយានយន្តឲ្យបានជាអតិបរមា<br>- ជំរុញឲ្យមានការប្រឡងបើកបរយានយន្តនៅលើផ្លូវសាធារណៈ។ |
| ៨ | ការគ្រប់គ្រងនិងវាយតម្លៃទៅលើសុវត្ថិភាពដឹកជញ្ជូនអ្នកដំណើរនិងទំនិញ | - ពង្រឹងភាពដឹកនាំ ការគ្រប់គ្រង និងការទទួលខុសត្រូវរបស់សមាគមឬក្រុមហ៊ុនដឹកជញ្ជូនតាមរយៈបទបញ្ជាផ្ទៃក្នុងស្តីពីសុវត្ថិភាព ការធ្វើផែនការ និងការគ្រប់គ្រងហានិភ័យដឹកជញ្ជូន<br>- ជំរុញការបណ្តុះបណ្តាលនិងការផ្សព្វផ្សាយឯកសារណែនាំស្តីពីការគ្រប់គ្រងសុវត្ថិភាពក្នុងការដឹកជញ្ជូនអ្នកដំណើរនិងទំនិញដល់សមាគមឬក្រុមហ៊ុននិងអ្នកបើកបរ<br>- ត្រួតពិនិត្យ តាមដាន និងវាយតម្លៃទៅលើសុវត្ថិភាពក្នុងការដឹកជញ្ជូនអ្នកដំណើរនិងទំនិញតាមរយៈការអនុវត្តច្បាប់និងការប្រមូលទិន្នន័យគ្រោះថ្នាក់ចរាចរណ៍។ |

តារាងអនុវត្តការងារមានភ្ជាប់ជាឧបសម្ព័ន្ធ។

## ៦- ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃ

គណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក បង្កើតយន្តការដើម្បីផ្តល់ព័ត៌មានតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយជាតិស្តីពីសុវត្ថិភាពចរាចរណ៍ផ្លូវគោក។ យន្តការទាំងនោះរួមមាន ការចុះត្រួតពិនិត្យការអនុវត្តការងារសុវត្ថិភាពចរាចរណ៍ ការធ្វើរបាយការណ៍លទ្ធផលអនុវត្តការងារនិងការស្រាវជ្រាវ ការវាយតម្លៃលើការប្រែប្រួល គោលបំណងនិងគោលដៅសុវត្ថិភាពចរាចរណ៍ ដែលបានកំណត់នៅក្នុងគោលនយោបាយជាតិស្តីពីសុវត្ថិភាពចរាចរណ៍ផ្លូវគោក។ ដំណើរការត្រួតពិនិត្យនេះនឹងត្រូវសម្របសម្រួលដោយការបង្កើតនូវគោល-ការណ៍ជាក់លាក់ ដូចជាគោលការណ៍តាមដាននិងវាយតម្លៃលើការពាក់មួកសុវត្ថិភាព ការបើកបរក្រោមឥទ្ធិពលជាតិស្រវឹង និងការបើកបរហួសល្បឿនកំណត់ជាដើម។

ប្រព័ន្ធព័ត៌មានជនរងគ្រោះនិងគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោក ជាយន្តការសំខាន់សម្រាប់ធ្វើការតាមដាននិងការវាយតម្លៃលើការប្រែប្រួលនៃគោលដៅសុវត្ថិភាពចរាចរណ៍។

លទ្ធផលចេញពីការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃ នឹងក្លាយជាអនុសាសន៍សម្រាប់ កែលម្អលើយុទ្ធសាស្ត្រនិងផែនការសកម្មភាពការងារសុវត្ថិភាពចរាចរណ៍។

## ៧- សេចក្តីសន្និដ្ឋាន

ទោះបីជាមានកត្តាខ្លះៗដែលនាំឲ្យមានការលំបាកនិងការប្រឈមក្នុងការឈានទៅរកការកាត់បន្ថយចំនួនអ្នកស្លាប់និងរបួសដោយគ្រោះថ្នាក់ចរាចរណ៍នៅព្រះរាជាណាចក្រកម្ពុជា ឲ្យមកកម្រិតទាបបំផុតនាពេលខាងមុខ តាមគោលដៅដែលបានកំណត់ក្នុងគោលនយោបាយជាតិស្តីពីសុវត្ថិភាពចរាចរណ៍ផ្លូវគោកនេះក៏ដោយ ក៏នៅមានហេតុផលនិងកត្តាវិជ្ជមានជា...

ជាច្រើនដែលនាំឲ្យព្រះរាជាណាចក្រកម្ពុជាសម្រេចបានជោគជ័យតាមគោលនយោបាយជាតិដែលបានអនុម័ត។

គោលនយោបាយជាតិស្តីពីសុវត្ថិភាពចរាចរណ៍ផ្លូវគោក បានទទួលការគាំទ្រយ៉ាងខ្លាំងក្លាពី **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។ ម្យ៉ាងទៀត គោលនយោបាយជាតិនេះតម្រូវឲ្យមានការចូលរួមនិងគាំទ្រពីគ្រប់ស្ថាប័នជាតិនិងអន្តរជាតិ ដែលជាកត្តាគន្លឹះក្នុងការកៀរគរធនធាន រួមមាន ធនធានមនុស្ស ហិរញ្ញវត្ថុ សម្ភារៈបរិក្ខារ និងបច្ចេកទេសតាមតម្រូវការចាំបាច់។

# ឧបសម្ព័ន្ធ

## ១- តារាងអនុវត្តការងារ

តារាងអនុវត្តការងារនេះ៖ គឺជាតារាងអនុវត្តរួមទៅតាមឆ្នាំដែលបានកំណត់(២០១១-២០២០)។ ស្ថាប័នទទួលខុសត្រូវនឹងរៀបចំផែនការសកម្មភាពលម្អិត ព្រមទាំងគម្រោងចំណាយលម្អិតរបស់ស្ថាប័ននីមួយៗសម្រាប់អនុវត្តការងារតាមឆ្នាំនីមួយៗ នៅរៀងរាល់១ឆ្នាំម្តង។

### ផែនការសកម្មភាពទី១ : ការគ្រប់គ្រងសុវត្ថិភាពចរាចរណ៍

| ចំណុចអាទិភាព | សកម្មភាព | អ្នកទទួលខុសត្រូវ | កាលបរិច្ឆេទដែលត្រូវអនុវត្ត (ខែ) | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ឆ្នាំ ១១ | ឆ្នាំ ១២ | ឆ្នាំ ១៣ | ឆ្នាំ ១៤ | ឆ្នាំ ១៥ | ឆ្នាំ ១៦ | ឆ្នាំ ១៧ | ឆ្នាំ ១៨ | ឆ្នាំ ១៩ | ឆ្នាំ ២០ |
